# ខ្លឹមសារសង្ខេបសាលដីកាលេខ២២៧ (២០១១) បទរំលោភសេពសន្ថវៈ

## ពាក្យគន្លឹះ៖ គោលការណ៍នីត្យានុកូលភាព ការផ្លាស់ប្តូរប្រភេទបទល្មើស បទរំលោភ ឬបទប៉ុនប៉ងរំលោភសេពសន្ថវៈ

## ១. អង្គហេតុនិងប្រវត្តិនីតិវិធី

កាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៦ ក្នុងភូមិដើមដូង (ស្រុកមោងឬស្សី) មានទង្វើប៉ុនប៉ងរំលោភសេពសន្ថវៈមួយ ត្រូវបានប្រព្រឹត្តលើក្មេងស្រីអាយុ៦ឆ្នាំ។ អង្គហេតុនេះ ត្រូវបានចោទជាបទប៉ុនប៉ងរំលោភសេពសន្ថវៈតាមមាត្រា៤នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ សាលាដំបូងខេត្តបាត់ដំបងបានបើកសសវនាការ និងចេញសាលក្រមលេខ២៨៩(ខ) ខែមិថុនា ឆ្នាំ២០០៦ សម្រេចឲ្យជនជាប់ចោទអាយុ២០ឆ្នាំ រួចផុតពីបទចោទ ក៏ប៉ុន្តែបង្គាប់ឲ្យម្តាយចេញសំណងជំងឺចិត្ត១លានរៀលដល់ជនរងគ្រោះ។ ព្រះរាជអាជ្ញារង បានប្តឹងប្រឆាំងនឹងសាលក្រមនេះ។ ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ បានអះអាងថាការសម្រេចឲ្យរួចខ្លួននេះមិនត្រូវទេ ដោយសារជនជាប់ចោទបានសារភាពថាបានប្រព្រឹត្ត គួរមានប្រតិកោសលវិច័យបញ្ជាក់ថា ជនជាប់ចោទមានវិកលចរិក។ សាលាឧទ្ធរណ៍ចេញសាលដីកាលេខ២៦០(ខ) ឆ្នាំ២០០៨ បដិសេធសាលក្រម និងប្តូរបទចោទទៅជារំលោភសេពសន្ថវៈវិញ និងផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារ១៥ឆ្នាំ។ ជនជាប់ចោទបានប្តឹងសាទុក្ខ។ ព្រះរាជអាជ្ញាអមតុលាការកំពូលអះអាងថា មានភស្តុតាងថា បានប្រព្រឹត្តបទប៉ុនប៉ងរំលោភសេពសន្ថវៈ។ តុលាការកំពូលបានចេញសាលដីកាលេខ២២៧ ក្នុងខែធ្នូ ឆ្នាំ២០១១។

## ២. សំអាងហេតុនិងសេចក្តីសម្រេច

តុលាការកំពូលបានពិចារណា និងយល់ឃើញថា៖ *ដោយក្រមព្រហ្មទណ្ឌបានចូលជាធរមាន ហើយបទល្មើសនេះការកំណត់ទណ្ឌកម្មក្នុងព្រហ្មទណ្ឌមានលក្ខណៈស្រាលជាងច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ គប្បីអនុវត្តតាមមាត្រា១០នៃក្រមព្រហ្មទណ្ឌ។* ...ខ្លឹមសារ*សម្រេចមកនេះពុំមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ទេ។*

**សម្រេច៖២.** បដិសេធសាលដីកាលេខ២៦០(ខ)...**៣.** បញ្ជូនសំណុំរឿង...ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះសាជាថ្មីឡើងវិញ។

## ៣. កំណត់សំគាល់

**១.** ពីថ្ងៃកើតហេតុឆ្នាំ២០០៦ មកដល់ឆ្នាំ២០១១ ចេញសាលដីកា មានរយៈពេលប្រហែល៥ឆ្នាំ។

**២.**រឿងនេះ ពាក់ព័ន្ធនឹងបញ្ហាច្បាប់ គឺគោលការណ៍នីត្យាកុលភាព ដែលទាក់ទងនឹងច្បាប់ដែលត្រូវយកមកអនុវត្ត និងប៉ះពាល់ផងដែរដល់រយៈពេលនៃទោស។ ច្បាប់ដាក់ទោសស្រាលជាង ដែលយកមកអនុវត្ត គឺក្នុងពេលដែលទោសប្រកាសមិនទាន់ជាស្ថាពរ។ ការពិតសវនាការសាលាឧទ្ធរណ៍ក្នុងឆ្នាំ២០០៨ ជាឆ្នាំដែលក្រមព្រហ្មទណ្ឌថ្មីមិនទាន់ចូលជាធរមាន ខណៈសំណុំរឿងនេះក្នុងដៃតុលាការកំពូល ក្រមព្រហ្មទណ្ឌបានចូលជាធរមានរួចហើយ។ ខ្លឹមសារនៃសាលដីកា មិនបានបង្ហាញថាមូលហេតុអ្វីបានជាតុលាការកំពូលមិនសម្រេចអង្គច្បាប់ខ្លួនឯង។ អ្នកនិពន្ធមិនមានសាលដីកាជំនុំជម្រះជាថ្មី ដោយសាលាឧទ្ធរណ៍ទេ៕ វាជារឿង គួរឲ្យតាមដាន និងសិក្សាបន្ត។

**៣.**មានការខ្វែងយោបល់រវាងព្រះរាជអាជ្ញា និងចៅក្រម។ ម្ខាងថាជាបទប៉ុនប៉ង ម្ខាងថាបទរំលោភសេពសន្ថវៈ។ រឿងនេះជាការសំខាន់ ពាក់ព័ន្ធនឹងការកំណត់បទល្មើស ហើយដែលរយៈពេលទោសអាចធ្ងន់ឬស្រាល ក៏អាចប្រែប្រួលផងដែរ។ មិនទាន់មានការបំភ្លឺជាក់លាក់អំពីភាពខុសគ្នារវាងបទប៉ុនប៉ងរំលោភ និងបទរំលោភទេ។ សាលដីកាក៏មិនបានបំភ្លឺ។

**ឯកសារយោងដទៃទៀត៖** តុលាការកំពូល បានសម្រេចស្រដៀងនេះក្នុងសាលដីកាលេខ៣៣៣ (ឆ្នាំ២០១៣)បទប្លន់, សាលដីកាតុលាការកំពូលេខ២៤៣ (២០១៣)បទប្លន់, សាលដីកាលេខ២៨៦ (២០១៣) បទក្លែងលិខិត, សាលដីកាលេខ៨ (២០០៤) ធាតុផ្សំនៃបទលួច។ អត្ថបទស្រាវជ្រាវពាក់ព័ន្ធ គោលការណ៍នីត្យានុកូល ឬភាពប្រាកដប្រជានៃច្បាប់។